ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលជំនួបរវាងឯកឧត្តម កែវ រ៉េមី ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ជាមួយ លោក Rory Mungoven ប្រធានការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក នៅទីក្រុងហ្សឺណែវ

នារសៀលថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥ ឯកឧត្តម **កែវ រ៉េមី** ទេសរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា បានអនុញ្ញាតឱ្យលោក **Rory Mungoven** ប្រធានការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិក នៅទីក្រុងហ្សឺណែវ (OHCHR) ចូលជួបពិភាក្សាការងារ នៅសាលប្រជុំរបស់គណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា (គ.ស.ម.ក.)។ កិច្ចជំនួបនេះផ្តោតលើការពង្រឹង និងគម្រោងកិច្ចសហប្រតិបត្តិការរវាង គ.ស.ម.ក. និងការិយាល័យអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនាពេលខាងមុខ។

ក្រៅពីស្វាគមន៍ លោក **Rory Mungoven** និងសហការី និងវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការរវាង គ.ស.ម.ក. និង OHCHR ប្រចាំប្រទេសកម្ពុជា នាពេលកន្លងមក ឯកឧត្តម **កែវ រ៉េមី** បានលើកឡើងពី**ការជំរុញការដោះលែងកងទ័ពកម្ពុជាទាំង១៨រូប ដែលកំពុងស្ថិតក្នុងការឃុំឃាំងរបស់កងទ័ពថៃ ការជំរុញការហាមឃាត់ការប្រើប្រាស់សព្វាវុធខុសច្បាប់អន្តរជាតិក្នុងពេលមានជម្លោះ និងការប៉ះទង្គិចគ្នារវាងប្រទេសកម្ពុជានិងប្រទេសថៃ**។ ទន្ទឹមនេះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានសម្តែងការខកចិត្តចំពោះប្រទេសស៊ុយអែតដែលជាប្រទេសគម្រូក្នុងការការពារសិទ្ធិមនុស្ស ដោយបានលក់យន្តហោះចម្បាំងប្រភេទ Gripen ឱ្យប្រទេសថៃអំឡុងពេលមានជម្លោះជាមួយនឹងប្រទេសកម្ពុជា។ ជាមួយគ្នានេះ ឯកឧត្តមទេសរដ្ឋមន្ត្រី បានគូសបញ្ជាក់ពីតួនាទីយ៉ាងសំខាន់របស់សិទ្ធិមនុស្ស ក្នុងការពារសណ្តាប់ធ្នាប់អន្តរជាតិ និងបានស្នើ លោក **Rory Mungoven** ចំពោះការធ្វើរបាយការណ៍សិទ្ធិមនុស្សអំពីប្រទេសកម្ពុជា សូមឱ្យឆ្លុះបញ្ចាំងពីការពិតជាក់ស្តែង។

ក្នុងកិច្ចជំនួបនេះ លោក **Rory Mungoven** បានថ្លែងអំណរគុណចំពោះឯកឧត្តមទេសរដ្ឋមន្ត្រីដែលបានចំណាយពេលដ៏មមាញឹក អនុញ្ញាតឱ្យរូបលោកនិងសហការី បានចូលជួបពិភាក្សាការងារ។ លោក **Rory Mungoven** បានកោតសរសើរពីកិច្ចខិតខំរបស់ គ.ស.ម.ក. ក្នុងការបង្ហាញពីសារៈសំខាន់នៃសិទ្ធិមនុស្សក្នុងការការពារសណ្តាប់ធ្នាប់អន្តរជាតិ និងការលើកកម្ពស់សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា។

លោក Rory Mungoven ក៏បានអរគុណចំពោះគ្រប់ញត្តិដ៏មានសារៈសំខាន់របស់ គ.ស.ម.ក. ដែលបានដាក់ទៅ **ឯកឧត្តមឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស** ផងដែរ។ លោកបានបញ្ជាក់ថា **ឯកឧត្តមឧត្តមស្នងការសិទ្ធិមនុស្ស** បានយកចិត្តទុកដាក់ខ្ពស់ចំពោះញត្តិទាំងនោះ និងបានតាមដានលើការអនុវត្តសេចក្តីថ្លែងការណ៍រួមរវាង ប្រទេសកម្ពុជា និងប្រទេសថៃ ដើម្បីសម្រេចបានដំណោះស្រាយសន្តិភាព។ ចំពោះសំណើទាំងពីររបស់ឯកឧត្តមទេសរដ្ឋមន្ត្រី លោកនឹងជំរុញកិច្ចការនេះបន្ថែម និងពាំនាំជូន **ឯកឧត្តមឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស**។ ទន្ទឹមនេះ លោក Rory Mungoven បានសាកសួរពីវឌ្ឍនភាពនៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស ផងដែរ។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានជម្រាបពីវឌ្ឍនភាពនៃសេចក្តីព្រាងច្បាប់ស្តីពីការបង្កើតស្ថាប័នជាតិសិទ្ធិមនុស្ស និងបានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បាននិងកំពុងជំរុញការអនុវត្តប្រព័ន្ធគាំពារសង្គម និងកិច្ចការអាទិភាពមួយចំនួនទៀត។

ជាកិច្ចបញ្ចប់ កិច្ចប្រជុំបានប្រព្រឹត្តទៅក្រោមបរិយាកាសស្និទ្ធស្នាល យោគយល់ និងសម្រេចបានលទ្ធផលគួរជាទីពេញចិត្ត៕

ថ្ងៃចន្ទ ៥រោច ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៥

អគារលេខ៣ ផ្លូវ VI.13 ភូមិទួលសំពៅ សង្កាត់ទួលសង្កែ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ
Building #3, Street VI.13, Toul Kok Village, Sangkat Toul Sangke, Khan Russey Keo, Phnom Penh Tel: (855) 23 882 065